**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៧១ សហវ.ប្រក

# ប្រកាស
## ស្តីពីការបង្កើតគណៈកម្មាធិការ
## សំរាប់កិច្ចសហប្រតិបត្តិការវិស័យហិរញ្ញវត្ថុរវាង កម្ពុជា និង ជប៉ុន
## របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃពី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤/អនក្រ/តត ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការងារចាំបាច់របស់ក្រសួង

# សំរេច

**ប្រការ ១:** បង្កើតគណៈកម្មាធិការមួយសំរាប់កិច្ចសហប្រតិបត្តិការវិស័យហិរញ្ញវត្ថុ រវាង កម្ពុជា និង ជប៉ុន របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាសភាពដូចតទៅ:

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម ខិន ឃន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានធនាគារជាតិ | អនុប្រធាន |
| ៣. លោក ម៉ី ទាវ៉ន់ | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ៤. លោក ទូច ឡេង | ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច | សមាជិក |
| ៥. លោក ហ៊ីច សុវណ្ណ | អនុប្រធានទី ១ ធនាគារជាតិ | សមាជិក |
| ៦. លោក អឿង ស៊ុនលី | អនុប្រធានទី ១ នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច | សមាជិក |
| ៧. លោក ឈី សែ | អនុប្រធានទី ១ នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន | សមាជិក |
| ៨. លោក ម៉ិញ ឆានកុសល | អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ៩. លោក រស់ សីលវ៉ា | អនុប្រធានអង្គភាពផែនការនីយកម្ម និង តាមដានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១០. លោក ហាច រតនៈ | អនុប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន | សមាជិក ។ |

**ប្រការ ២:** គណៈកម្មាធិការនេះ មានភារៈកិច្ចទទួលអនុវត្តកិច្ចសហប្រតិបត្តិការរួមលើវិស័យហិរញ្ញវត្ថុ ជាមួយនឹងគណៈកម្មាធិការទទួលបន្ទុកកិច្ចសហប្រតិបត្តិការវិស័យហិរញ្ញវត្ថុរបស់ជប៉ុន ។

**ប្រការ ៣:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ មីនា ឆ្នាំ ២០០៤

គាត ឈន់

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការផ្ទាល់មុខងារសាធារណៈ
  «ដើម្បីជូនជ្រាប»
- ដូចប្រការ ៣
- កាលប្បវត្តិ-ឯកសារ